ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

របាយការណ៍កិច្ចប្រជុំ
ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែសីហា

១. ថ្ងៃ ខែ ឆ្នាំ៖ ថ្ងៃអង្គារ ១២កើត ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ត្រូវថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៦

២. ទីកន្លែង៖ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ(Zoom)

៣. ប្រធាន និងសមាសភាពចូលរួម ៖

៣.១ ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន៤៣រូប និងតាមប្រព័ន្ធអនឡាយចំនួន៣៨គណនី។

៤. របៀបវារៈ៖

៤.១-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២-បទបង្ហាញស្តីពី ការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ ២០២៣–២០២៨៖ ការទាញយកមេរៀន និងលទ្ធផលគន្លឹះពីសន្និសីទអន្តរជាតិ ស្តីពីអេដស៍ លើកទី២៦។

៤.៣- មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉ែត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជំងឺអេដស៍។

៥. លទ្ធផល ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉ែត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែសីហា ឆ្នាំ២០២៦ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ឯកឧត្តមបណ្ឌិត អគ្គលេខាធិការ បានមានប្រសាសន៍ជូនអង្គប្រជុំឱ្យបានជ្រាបថា កិច្ចប្រជុំថ្ងៃនេះ បានផ្តោតលើគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣ ២០២៨ និងលទ្ធផលគន្លឹះពីសន្និសីទអន្តរជាតិស្តីពីអេដស៍ លើកទី២៦។។

ប្រទេសកម្ពុជាបានទទួលជោគជ័យក្នុងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលដៃមេរោគអេដស៍ និងជំងឺអេដស៍។ គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨៖

- គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ ក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។
- ចក្ខុវិស័យគឺ ប្រទេសកម្ពុជាជាប្រទេសមួយដែលគ្មានការគំរាមកំហែងពីមេរោគអេដស៍និងជំងឺអេដស៍ ព្រមទាំងធានាថា ប្រជាជនកម្ពុជាមានសុខភាពល្អ និងរស់នៅប្រកបដោយសុខុមាលភាព គ្មានការភ័យខ្លាចដោយសារជំងឺអេដស៍។
- បច្ចុប្បន្នភាពស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍ នៅប្រទេសកម្ពុជាមាន ៧៦ ០០០នាក់, ករណីឆ្លងថ្មីមានប្រមាណ ៩៦០នាក់, ករណីស្លាប់មានប្រមាណ ១.០០០នាក់, អត្រាប្រាំឡង់មនុស្សពេញវ័យអាយុពី១៥-៤៩ឆ្នាំមាន ០,៥%។
- ស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍សកល បានបង្ហាញនៅក្នុងសន្និសីទអន្តរជាតិ ស្តីពីអេដស៍លើកទី២៦ តាមរបាយការណ៍ប្រទេសចំនួន ១១ សម្រេចបានគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ ២០២៥ ក្នុងចំណោមនោះប្រទេសកម្ពុជាទទួលបានចំណាត់ថ្នាក់លេខ២នៅក្នុងសកល និងនៅក្នុងអាស៊ីប៉ាស៊ីហ្វិកប្រទេសកម្ពុជាទទួលបានចំណាត់ថ្នាក់លេខ១។
- លទ្ធផលគន្លឹះនៃសន្និសីទអន្តរជាតិស្តីពីអេដស៍លើកទី២៦
  - សន្និសីទអន្តរជាតិស្តីពីអេដស៍លើកទី២៦ (The 26th International AIDS Conference) ដែលរៀបចំដោយសមាគមអេដស៍អន្តរជាតិ "International AIDS Society (IAS)" បានប្រារព្ធឡើងនៅទីក្រុងរីយូដេជាណេរ៉ូ ប្រទេសប្រេស៊ីល (ថ្ងៃទី ២៦–៣១ ខែកក្កដា ឆ្នាំ ២០២៦) ក្រោមប្រធានបទមួយចម្បង៖ «គិតឡើងវិញ ស្ថាបនាឡើងវិញ ឈរឡើងវិញ" ដោយមានអ្នកចូលរួមប្រមាណ ៧.៥០០ នាក់ ដែលចូលរួមផ្ទាល់ និងតាមអនឡាញ រួមមាន ប្រធានបទសន្និសីទ "គិតឡើងវិញ ស្ថាបនាឡើងវិញ ឈរឡើង" ប្រធានបទនេះបង្ហាញពីតម្រូវការដើម្បី៖
    - ពិចារណាឡើងវិញអំពីការឆ្លើយតបនឹងមេរោគអេដស៍ ជាសកលក្នុងស្ថានភាពភូមិសាស្ត្រ និងហិរញ្ញវត្ថុដែលកំពុងផ្លាស់ប្តូរ។
    - ស្ថាបនាកម្មវិធីជំងឺអេដស៍ដែលមានភាពរឹងមាំ និងចីរភាពឡើងវិញ។
    - រួមគ្នាឡើងតាមវិទ្យាសាស្ត្រ នវានុវត្តន៍ សិទ្ធិមនុស្ស និងភាពជាអ្នកដឹកនាំសហគមន៍ ដើម្បីសម្រេចគោលបំណងបញ្ចប់ជំងឺអេដស៍ជាហានិភ័យសុខភាពសាធារណៈនៅឆ្នាំ២០៣០។
  - ប្រឈមមុខនឹងបរិបទដែលមានភាពងាយរងគ្រោះ UNAIDS បានចេញផ្សាយរបាយការណ៍របស់ខ្លួនដោយលើកឡើងថា ទោះបីជាការស្លាប់ និងការឆ្លងថ្មីដែលទាក់ទងនឹងជំងឺអេដស៍ស្ថិតនៅកម្រិតទាបបំផុតក្នុងប្រវត្តិសាស្ត្រ ការឆ្លើយតបជាសកលនៅតែស្ថិតក្នុងស្ថានភាពងាយរងគ្រោះដោយសារការកាត់បន្ថយថវិកាអន្តរជាតិ និងភាពតានតឹងភូមិសាស្ត្រនយោបាយកើនឡើង។
  - សេចក្តីសង្ខេបវិទ្យាសាស្ត្រ និងការច្នៃប្រឌិត ការរីកចម្រើនក្នុងការការពារ៖ សន្និសីទបានបង្ហាញឧបករណ៍ការពារដែលមានប្រសិទ្ធិភាពរយៈពេលវែង ដូចជា lenacapavir ចាក់ពីរដងក្នុងមួយឆ្នាំ និងការសោកល្បងដំណាក់កាលចុងក្រោយសម្រាប់ PrEP លេប (Oral PrEP) ប្រចាំខែ។

- អ្នកស្រាវជ្រាវ អ្នកជំនាញសុខាភិបាល អ្នកគាំទ្រសហគមន៍ និងអ្នកកំណត់គោលនយោបាយ បានប្រមូលផ្តុំគ្នាដើម្បីពិភាក្សាអំពីការអភិវឌ្ឍសំខាន់ៗក្នុងការព្យាបាលជំងឺអេដស៍ វិទ្យាសាស្ត្រ បង្ការ និងយុទ្ធសាស្ត្រសុខាភិបាលពិភពលោក។

- ការណែនាំ WHO ដែលបានធ្វើបច្ចុប្បន្នភាព៖ WHO បានចេញមគ្គុទេសក៍បច្ចេកទេសដែលបានធ្វើបច្ចុប្បន្នភាព សម្រាប់ការព្យាបាលរយៈពេលវែង ការការពារជាមុនការប៉ះពាល់បន្តែម (PrEP) និង DoxyPEP សម្រាប់ជំងឺកាមរោគ។
  - សិទ្ធិមនុស្ស និងសកម្មភាពដឹកនាំដោយសហគមន៍ ប្រជាជនគន្លឹះដែលមានហានិភ័យ៖ ទិន្នន័យដែលបានបង្ហាញពីការធ្លាក់ចុះយ៉ាងខ្លាំងនៃសេវាកម្មសម្រាប់បុរសរួមភេទជាមួយបុរស អ្នកបម្រើសេវាកម្សាន្ត ស្ត្រីបំប្លែងភេទ និងអ្នកប្រើប្រាស់គ្រឿងញៀន។
  - "គិតឡើងវិញ ស្តាបនាឡើងវិញ ក្រោកឡើង" សន្និសីទបានអំពាវនាវឱ្យផ្លាស់ប្តូរពីការពឹងផ្អែកលើអ្នកបរិច្ចាគបែបបុរាណទៅរកអធិបតេយ្យ សុខភាពហិរញ្ញប្បទាន សុខភាពក្នុងស្រុកប្រកបដោយនិរន្តរភាព និងការបញ្ចូលអង្គការដឹកនាំដោយសហគមន៍ដោយផ្ទាល់ទៅក្នុងប្រព័ន្ធសុខាភិបាលមូលដ្ឋានជាតិ។
- មេរៀនសំខាន់ៗសម្រាប់កម្ពុជា
  - សន្និសីទអន្តរជាតិស្តីពីអេដស៍លើកទី២៦ ដែលបានប្រព្រឹត្តទៅនៅទីក្រុង Rio de Janeiro ប្រទេសប្រេស៊ីល បានបង្កើតជាចលនាសកលថ្មីមួយក្នុងការជំរុញការបញ្ចប់អេដស៍ត្រឹមឆ្នាំ ២០៣០។ សម្រាប់ប្រទេសកម្ពុជា លទ្ធផល និងការពិភាក្សាផ្លាស់ប្តូរបទពិសោធន៍ក្នុងសន្និសីទនេះ បានផ្តល់នូវមេរៀន និងទិសដៅយុទ្ធសាស្ត្រសំខាន់ៗមួយចំនួន ដើម្បីពង្រឹងការឆ្លើយតបទៅនឹងមេរោគអេដស៍។
  - **ការទាញយកផលប្រយោជន៍ពីឱសថបង្ការ និងព្យាបាលជំនាន់ថ្មី** កម្ពុជាអាចសិក្សាលទ្ធភាពក្នុងការដាក់បញ្ចូល និងពង្រីកការប្រើប្រាស់ថ្នាំបង្ការរយៈពេលវែងនេះ សម្រាប់ក្រុមប្រជាជនគន្លឹះ (Key Populations) ដែលពិបាកក្នុងការលេបថ្នាំ PrEP ប្រចាំថ្ងៃ ដើម្បីកាត់បន្ថយអត្រាឆ្លងថ្មីឱ្យកាន់តែមានប្រសិទ្ធភាព។
  - **ចីរភាពហិរញ្ញវត្ថុ និងការបង្កើនថវិកាជាតិ** ការប្រឈមនៃការថយចុះមូលនិធិអន្តរជាតិ (ដូចជា Global Fund ឬ PEPFAR)កម្ពុជាត្រូវបន្តពង្រឹងយន្តការ **"អន្តរកាលហិរញ្ញប្បទាន"** ដោយបង្កើនការបែងចែកថវិកាជាតិ (National Budget) និងការទាញយកកញ្ចប់គាំពារសង្គម (មូលនិធិសមធម៌សុខាភិបាល/ប.ស.ស.) ដើម្បីធានាថាការផ្តល់សេវាពិនិត្យ និងព្យាបាលមេរោគអេដស៍នៅតែមានចីរភាព និងមិនរអាក់រអួល។
  - **ការពង្រឹងតួនាទី និងការដឹកនាំដោយសហគមន៍** ពង្រឹង និងពង្រីកការតាមដានសេវាដោយសហគមន៍ (Community-Led Monitoring - CLM) និងការផ្តល់កិច្ចសន្យាសេវាសាធារណៈទៅឱ្យអង្គការសង្គមស៊ីវិល និងសហគមន៍ (Non-state agent) ដើម្បីឆ្លើយតបទៅនឹងការរើសអើង និងចូលទៅដល់ក្រុមប្រឈមដែលលាក់មុខ។
  - **ការធ្វើសមាហរណកម្មសេវាអេដស៍ទៅក្នុងប្រព័ន្ធសុខាភិបាលទូទៅ** ការផ្តល់សេវាអេដស៍នៅកម្ពុជាគួរតែទួញភ្ជាប់ជាកញ្ចប់តែមួយជាមួយនឹងសេវាសុខភាពផ្លូវចិត្ត សុខភាពបន្តពូជ

និងការពិនិត្យជំងឺមិនឆ្លង (NCDs) នៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ដើម្បីកាត់បន្ថយការរើសអើង និងបង្កើនភាពងាយស្រួលដល់ប្រជាពលរដ្ឋ។

- **ការប្រើយុទ្ធសាស្ត្រឌីជីថលសម្រាប់ក្រុមយុវវ័យ** ពង្រឹងការប្រើប្រាស់កម្មវិធីទូរស័ព្ទ (Mobile Apps) បណ្តាញសង្គម និងប្រព័ន្ធពិគ្រោះយោបល់អនឡាញ សម្រាប់ការអប់រំ ការវាយតម្លៃហានិភ័យដោយខ្លួនឯង និងការបញ្ជូនទៅទទួលសេវាសាកល្បងលឿន (Self-testing)។

ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉ែត បានធ្វើការបញ្ជាក់ថា ការប៉ាន់ស្មានមេរោគអេដស៍ថ្មី បានបង្ហាញថា ការកើនឡើងសមាមាត្រនៃការឆ្លង មេរោគអេដស៍ថ្មីគឺស្ថិតក្នុងចំណោមបុរស និងក្មេងប្រុស។ តាមចំនួនប្រជាជន៨៣% នៃការឆ្លងមេរោគអេដស៍ថ្មី សរុបគឺស្ថិតក្នុងចំណោម ប្រជាជនគន្លឹះ បុរសរួមភេទជាមួយបុរស ស្ត្រីបំប្លែងភេទ អ្នកដែលប្រើប្រាស់និងចាក់ថ្នាំញៀន និងដៃគូផ្លូវភេទរបស់ពួកគេ។ សមិទ្ធិផលរបស់ប្រទេសកម្ពុជា ត្រូវបានចាត់ទុកជាគំរូ ក្នុងការសម្រេចបានខ្ពស់បំផុតនូវអត្រាទទួលសេវាព្យាបាល និងអត្រាកាត់បន្ថយមេរោគមកកម្រិតទាបបំផុតក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារប្រយុទ្ធនឹងមេរោគអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នា រវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិ ដែលរួមមានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ឱ្យចំលើការងារជាអាទិភាព ពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ និងជាបណ្តើរៗធានាចីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងសូមជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយពីការបង្ការការចម្លងមេរោគអេដស៍ ដល់គ្រប់មជ្ឈដ្ឋាន ជាពិសេសក្រុមយុវវ័យ។

ថ្ងៃចន្ទ ៣រោច ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៦

	បានពិនិត្យត្រឹមត្រូវ	អ្នកធ្វើរបាយការណ៍
បានឃើញ និងឯកភាព ប្រធានអង្គប្រជុំ	ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រកពធនធាន	
បណ្ឌិត ឈឹម យិនដារ៉ែត	**វេជ្ជ. ហួត សេរីវុឌ្ឍ**	**ស៊ុំ ផល្លា**